**ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា**

**CAMBODIA WATCHDOG COUNCIL INTERNATIONAL**

គ្រីស្ទានសាន់ (ន័រវេស៍) ថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០២០

# សេចក្តីបញ្ជាក់

## ជុំវិញការបោះតង់នៃយោធាវៀតណាម រំលោភចូលទឹកដីខ្មែរ ស្រុកកោះធំ ខេត្តកណ្តាល

ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា សូមស្វាគមន៍ចំពោះចំណុចខ្លះ ដែលលោក វ៉ា គឹមហុង ទេសរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការចម្រុះព្រំដែនកម្ពុជា មានសេចក្តីក្លាហានលើកឡើងថា វៀតណាម រំលោភសេចក្តីថ្លែងការណ៍រួមស្តីពី **«តំបន់ស ឬ តំបន់មានជម្លោះ»** ដែលបានធ្វើរួមគ្នាកាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៩៥។ ជាមួយគ្នានេះ យើងខ្ញុំក៏សូមកោតសរសើរ ចំពោះចំណាត់ការរបស់អាជ្ញាធរសមត្ថកិច្ច ខេត្តកណ្តាល ចុះរុះរើការបោះតង់ទាំង ៩ កន្លែងរបស់យោធាវៀតណាម ដែលរំលោភចូលក្នុងទឹកដីខ្មែរ នៅតំបន់ព្រំដែន ស្រុកកោះធំ ខេត្តកណ្តាល នាថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២០។

តាមការពិតទៅ សេចក្តីថ្លែងការណ៍រួម ឆ្នាំ១៩៩៥ នោះ បានធ្វើឡើងចាញ់ប្រៀបភាគីវៀតណាមរួចហើយថា ជាការដាក់ទឹកដីកម្ពុជាខ្លួនឯង ជា«**តំបន់ស**» ដោយហាមប្រាមពលរដ្ឋខ្មែរ មិនឲ្យចូលទៅធ្វើស្រែចម្ការរបស់ខ្លួន ដោយទុកលទ្ធភាពឲ្យរដ្ឋាភិបាលនៃប្រទេសទាំងពីរ ដោះស្រាយបញ្ចប់ជម្លោះជាមុនសិន។

ការដោះស្រាយជម្លោះព្រំដែន តាមសន្ធិសញ្ញាព្រំដែនថ្មី ឆ្នាំ២០០៥ បានបញ្ចប់ទៅដោយការបោះបង្គោលព្រំដែនថ្មីៗ ៣១៥ បង្គោល ឬស្មើ ៨៤% ធ្វើឲ្យពលរដ្ឋខ្មែរ បាត់បង់ដីស្រែចំការរបស់ខ្លួន ទៅខាងវៀតណាម។

ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា សូមរក្សាសិទ្ធិជំទាស់ជាដាច់ខាត ចំពោះកលើកឡើងរបស់លោក វ៉ា គឹមហុង ថ្លែងប្រាប់វិទ្យុអាស៊ីសេរី នៅថ្ងៃទី២៨ មេសាថា *«តំបន់នោះ យើងដាក់ក្នុងតំបន់ ដែលយើងស្នើឱ្យភាគីបារាំង គេមកជួយនៅថ្ងៃក្រោយ ថ្ងៃណាគេមកជួយចម្លងផែនទីបោន [Bonne] ពីខ្នាត ១/១០០ពាន់ ទៅជាផែនទីយូធីអឹម [UTM] ខ្នាត ១/ ៥០ពាន់»*។

ក្រុមការងារយើង ធ្លាប់បានបញ្ជាក់ច្រើនលើកច្រើនសារួចហើយថា ក្នុងស្ថានភាពប្រទេសកម្ពុជា នៅតែគ្មានឯកភាពជាតិដូចសព្វថ្ងៃនេះ រដ្ឋាភិបាលកម្ពុជា មិនត្រូវធ្វើការបោះបង្គោលព្រំដែន និងមិនត្រូវមានការចម្លង ឬបម្លែងខ្នាតផែនទីអ្វីទាំងអស់ ដើម្បីបំពេញបំណងតាមការចង់បានពីភាគីវៀតណាមឡើយ។

ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា អំពាវនាវដល់រដ្ឋាភិបាលកម្ពុជា ត្រូវតែពិចារណាឡើងវិញជាថ្មី ជំរុញការដាក់«**មោឃភាព**» **នូវសន្ធិសញ្ញាមិនស្មើភាពគ្នា រវាងកម្ពុជា និងវៀតណាម** ពោលគឺសន្ធិសញ្ញាព្រំដែនបំពេញបន្ថែម ឆ្នាំ២០០៥ និងសន្ធិសញ្ញាព្រំដែនបំពេញបន្ថែម ឆ្នាំ២០១៩ ដែលបានបំពេញខ្លឹមសារបន្ថែម ទៅលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ ឆ្នាំ១៩៨៥ ជាសន្ធិសញ្ញាខុសច្បាប់ ដែលផ្ទុយនឹងកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ១៩៩១ និងផ្ទុយពីរដ្ឋធម្មនុញ្ញកម្ពុជា មាត្រា២ និងមាត្រា៥៥ ព្រមទាំងត្រូវលុបចោល នូវសន្ធិសញ្ញា និងកិច្ចព្រមព្រៀងនានា ដែលធ្វើឡើងនៅមុនទសវត្សរ៍ទី៩០។

ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា បន្តជំរុញដល់រដ្ឋាភិបាលកម្ពុជា ត្រូវលើកបញ្ហាជម្លោះព្រំដែននេះ **ទៅកាន់សហប្រធានកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ១៩៩១** និងករណីមួយចំនួនទៀត **ដូចជាចង្កោមកោះត្រល់** ជាដើម ទៅកាន់តុលាការយុត្តិធម៌អន្តរជាតិ នៅពេលណាពិភពលោក ផុតគ្រោះពីវិបត្តិសុខភាពនៃជំងឺកូវីដ១៩។

**ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា**

**ប្រធាន**

**ម៉ែន ណាត**

Address: Senterveien 54, Apartment 112, 4790 Lillesand, NORWAY /Contact nathamonin@gmail.com /
Hompage: https://cwcicambodia.net